**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ៤២៦៦ សទណ.អាក

ថ្ងៃ ចន្ទ ៣ រោច ខែ ជេស្ឋ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ មិថុនា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអនុវត្តវិធានការបន្ថែមរបស់រាជរដ្ឋាភិបាលលើការលើកលែងការបង់កម្រៃបន្តអាជ្ញាបណ្ណទេសចរណ៍គ្រប់ប្រភេទសម្រាប់ឆ្នាំ២០២១

អនុវត្តតាមសេចក្តីប្រកាសព័ត៌មានរបស់រាជរដ្ឋាភិបាល ស្តីពីវិធានការបន្ថែមសំដៅជួយដល់វិស័យឯកជន និងកម្មករ-និយោជិត ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងវិធានការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចក្រោយពីវិបត្តិនៃជំងឺនេះ (ជុំទី៤ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០) ក្រសួងទេសចរណ៍សូមជូនដំណឹងដល់សមាគមឧស្សាហកម្មទេសចរណ៍ លោក-លោកស្រីជាម្ចាស់អាជីវកម្មទេសចរណ៍គ្រប់ប្រភេទ មេត្តាជ្រាបថា៖

១. លើកលែងការបង់កម្រៃបន្តអាជ្ញាបណ្ណទេសចរណ៍គ្រប់ប្រភេទសម្រាប់ឆ្នាំ២០២១ ចំពោះអាជ្ញាបណ្ណទេសចរណ៍ដែលស្ថិតក្នុងសុពលភាព។ អាជីវកម្មទេសចរណ៍គ្រប់ប្រភេទនៅតែមានកាតព្វកិច្ចដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬរដ្ឋបាលរាជធានីខេត្ត ឬរដ្ឋបាល ក្រុង ស្រុក ខណ្ឌ (ទៅតាមទំហំអាជីវកម្មទេសចរណ៍ដែលក្រសួងទេសចរណ៍បានធ្វើប្រតិភូកម្មកន្លងមក) ក្នុងអំឡុងពេលនៃការលើកលែងនេះ។

២. រក្សាការបង់កម្រៃអាជ្ញាបណ្ណទេសចរណ៍គ្រប់ប្រភេទចំពោះអាជីវកម្មទេសចរណ៍ ដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ថ្មី ឬបន្តក្នុងឆ្នាំ២០២០ និងស្នើសុំអាជ្ញាបណ្ណទេសចរណ៍ថ្មី សម្រាប់ឆ្នាំ២០២១។

៣. រក្សាការបង់កម្រៃសេវាសាធារណៈចំពោះការស្នើសុំចំណាត់ថ្នាក់សេវាកម្មទេសចរណ៍គ្រប់ប្រភេទ។

៤. រក្សាការអនុវត្តការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអាជីវកម្មទេសចរណ៍ដែលហួសសុពលភាពអាជ្ញាបណ្ណទេសចរណ៍ និងអាជីវកម្មដែលបានប្រព្រឹត្តខុសបទល្មើសផ្សេងៗចែងក្នុងឧបសម្ព័ន្ធ៣នៃប្រកាសអន្តរក្រសួងលេខ១៦០ប្រក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យជាប្រាក់ដោយក្រសួងទេសចរណ៍ ប៉ុន្តែ ការបង់កម្រៃសេវាសាធារណៈសម្រាប់ការបន្តអាជ្ញាបណ្ណទេសចរណ៍សម្រាប់ឆ្នាំ២០២១ នៅតែត្រូវបានលើកលែង។

៥. ការលើកលែងការបង់កម្រៃបន្តអាជ្ញាបណ្ណទេសចរណ៍គ្រប់ប្រភេទ នឹងត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

ក

សម្រាប់ព័ត៌មានបន្ថែម លោក លោកស្រីអាចទំនាក់ទំនងមកក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី ខេត្ត ឬតាមរយៈទូរស័ព្ទលេខ 092 779 833 ឬ 089 767 664 ឬ 011 833 318។

ទទួលបានសេចក្តីជូនដំណឹងនេះ សូម **សមាគមឧស្សាហកម្មទេសចរណ៍ លោក លោកស្រីជាម្ចាស់អាជីវកម្មទេសចរណ៍គ្រប់ប្រភេទ** មេត្តាជ្រាបជាព័ត៌មាន។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន៖**
- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- សហព័ន្ធទេសចរណ៍កម្ពុជា (CTF)
- សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)
- សមាគមសណ្ឋាគារកម្ពុជា (CHA)
- សមាគមភោជនីយដ្ឋានកម្ពុជា (CRA)
- សមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា (PATA)
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជា
- សមាគមដឹកជញ្ជូនទេសចរណ៍កម្ពុជា
- ឯកសារកាលប្បវត្តិ